## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ទេសរដ្ឋមន្ត្រី**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា
## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
## ថ្លែងក្នុងឱកាសបិទ
## កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០១៩

**សណ្ឋាគារសុខាមិត្តភាព ខេត្តកែប**
**ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៩**

ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលកំពុងមានវត្តមានដ៏ឧត្តុង្គឧត្តមក្នុងកិច្ចប្រជុំនាពេលនេះ!

ឆ្លងកាត់ការចំណាយពេលដ៏មានតម្លៃពេញមួយព្រឹក ដែលសម័យប្រជុំពេញអង្គរបស់យើងបានធ្វើបទបង្ហាញ រួមជាមួយនឹងការពិភាក្សា និងផ្តល់ជាយោបល់យ៉ាងផុសផុល ដែលនាំឱ្យសម័យប្រជុំពេញអង្គរបស់យើងទាំងមូលទទួលបាននូវលទ្ធផលគួរជាទីមោទនៈ សមស្របទៅនឹងកម្មវត្ថុនៃកិច្ចប្រជុំនាពេលនេះ ដែលខ្ញុំសូមសង្ខេបជូនដូចតទៅ ៖

**ទី១ :** ការអនុម័តជាគោលការណ៍នូវរបាយការណ៍វឌ្ឍនភាព ប្រសិទ្ធភាព និងសមិទ្ធផលក្នុងការឆ្លើយតបជាតិទូលំទូលាយ និងពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍៦ខែដើមឆ្នាំ២០១៩។

**ទី២ :** ការអនុម័តជាគោលការណ៍នូវ ផែនការជាតិឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍សម្រាប់រយៈពេល ៦ខែចុងឆ្នាំ២០១៩។

**ទី៣ :** សមាជិក សមាជិកានៃកិច្ចប្រជុំពេញអង្គបានប្តេជ្ញាចិត្តក្នុងការបន្តរៀបចំផែនការអនុវត្ត "សេចក្តីជូនដំណឹងលេខ ២១៣សជណ.សស" ឱ្យមានប្រសិទ្ធភាពខ្ពស់។ និង

**ទី៤ :** កិច្ចប្រជុំពេញអង្គបានឯកភាពអនុម័ត ចេញនូវសេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០១៩ សម្រាប់បន្តអនុវត្តការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ឆ្ពោះទៅសម្រេចបាននូវគោលដៅ៩៥-៩៥-៩៥ នាឆ្នាំ២០២៥។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី!***

ទោះបីជាពេលវេលារបស់យើងមានពេលតែមួយព្រឹកក៏ពិតមែន តែដោយសារតែមានការចូលរួមយ៉ាងសកម្មពី ឯកឧត្តម លោកជំទាវ លោក លោកស្រី បានធ្វើឱ្យពេលវេលាដ៏មានតម្លៃរបស់យើងអាចទទួលបាននូវផ្លែផ្កាដែល ខ្ញុំសូមយកឱកាសនេះសម្តែងនូវការកោតសរសើរដ៏ស្មោះស្ម័គ្របំផុតជូនសមាជិក សមាជិកានៃអង្គពិធីទាំងមូល។

ខ្ញុំសូមអនុញ្ញាតឆ្លៀតក្នុងឱកាសមុនបិទសម័យប្រជុំពេញអង្គរបស់យើង ផ្តល់ជូននូវការចាប់អារម្មណ៍បូកសរុបនូវលទ្ធផលជារួមដែលទទួលបានពីកិច្ចប្រជុំនេះដូចខាងក្រោម ៖

១) ជារួម យើងទាំងអស់គ្នាពិតជាបានខិតខំអនុវត្តផែនការសកម្មភាព៦ខែដើមឆ្នាំ២០១៩ ទៅតាមក្រសួង ស្ថាប័នជាតិ អន្តរជាតិ សង្គមស៊ីវិល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គ្រាន់តែលទ្ធផលដែលយើងទទួលគឺអាចខុសៗគ្នាទៅតាមស្ថានភាពជាក់ស្តែងរបស់ស្ថាប័ននីមួយៗ។

២) ប្រទេសកម្ពុជារបស់យើងនៅតែមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការត្រួតពិនិត្យការរាលដាលមេរោគអេដស៍ឱ្យបន្តធ្លាក់ចុះជាបន្តបន្ទាប់ទៅទៀត មានលទ្ធភាពផ្តល់ការថែទាំ និងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ដល់អ្នកដែលត្រូវការបានលើសពី៨០% និងពុំមានរបាយការណ៍ស្តីពីការរើសអើងអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ទេ។

៣) អបអរសាទរចំពោះក្រសួងផែនការ ដែលបានសម្របសម្រួលបញ្ចូលអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ទៅក្នុងក្រុមប្រជាជនដែលបានទទួលប័ណ្ណក្រីក្រជាបន្តបន្ទាប់។

៤) លើកទឹកចិត្តក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលបានជួយបង្កើន និងសម្របសម្រួលដល់ការប្រើប្រាស់ថវិកាជាតិ ក្នុងការប្រយុទ្ធនឹងជំងឺអេដស៍។

៥) លើកទឹកចិត្តក្រសួង រដ្ឋលេខាធិការដ្ឋាន ខេត្តរាជធានីដែលមិនទាន់បានផ្ញើរបាយការណ៍មកកាន់ លេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ឱ្យផ្ញើរបាយការណ៍ឱ្យទាន់ពេលវេលា និង

៦) កង្វះខាតថវិកានៅតែជាបញ្ហាចម្បងមួយ រារាំងដល់ការអនុវត្តផែនការសកម្មភាពឱ្យបានពេញលេញទៅតាមការគ្រោងទុក ឬក៏លទ្ធភាពក្នុងការពង្រីកអត្រាគ្របដណ្តប់ទៅកាន់ភូមិសាស្ត្រថ្មី ក្រុមគោលដៅថ្មី។

ជាមួយគ្នានេះផងដែរ ខ្ញុំសូមផ្តល់ជូននូវអនុសាសន៍មួយចំនួនដូចខាងក្រោម ៖

១) អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវប្រមូលរាល់អនុសាសន៍ទាំងអស់ដែលបានអនុម័តជាគោលការណ៍នៅក្នុងកិច្ចប្រជុំនេះ ទៅរៀបចំបញ្ចប់របាយការណ៍៦ខែដើមឆ្នាំ២០១៩ និងកែលម្អនូវគម្រោងផែនការសកម្មភាព៦ខែចុងឆ្នាំ ២០១៩។

២) បន្តចូលរួមជា “**ចលនាជាតិមួយ**” ក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

៣) លើកទឹកចិត្តជូនសមាជិកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យខិតខំបង្កើនសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីឈានទៅសម្រេចឱ្យបាននូវគោលដៅសូន្យបី និងដោយឡែកសម្រាប់ក្រសួងសុខាភិបាលក្នុងការអនុវត្តគោលដៅ៩៥-៩៥-៩៥ តាមកាលកំណត់នៅឆ្នាំ២០២៥-២០៣០។

៤) បន្តអនុវត្តសេចក្តីសម្រេចចិត្តនៃសម័យប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០១៩ ដែលទើបបានទទួលការអនុម័តនាពេលនេះ។

៥) សូមជំរុញលើកទឹកចិត្តក្រសួង ស្ថាប័នដែលពុំទាន់បានទទួលថវិកាពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកសំណើថវិកាឆ្នាំ២០២០ក្នុងកញ្ចប់នៃផែនការថវិការបស់ក្រសួង ស្ថាប័នសាមី។

៦) សូមគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត ជំរុញការផ្តល់របាយការណ៍ជាទៀងទាត់ មកអាជ្ញាធរជាតិ (ប្រចាំឆមាស ប្រចាំឆ្នាំ ប្រចាំខែ) ប្រយុទ្ធនឹងជំងឺអេដស៍តាម រយៈការពង្រឹងការអនុវត្តគោលការណ៍បីមួយៈ ស្ថាប័នដឹកនាំសម្របសម្រួលតែមួយ ផែនការយុទ្ធសាស្ត្រតែមួយ និងប្រព័ន្ធតាមដានត្រួតពិនិត្យ

តែមួយ។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នឹងធ្វើការវាយតម្លៃ និងចេញប័ណ្ណសរសើរ នៅក្នុងកិច្ចប្រជុំពេញអង្គ លើកទី២ នៅចុងឆ្នាំ២០១៩។

៧) អំពាវនាវដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបន្តធ្វើវិនិយោគថវិកាជាតិបន្ថែមទៀត ដើម្បីពន្លឿនការសម្រេចបាននូវគោលដៅទៅតាមការគ្រោងទុក។ និង

៨) អំពាវនាវដល់ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនក្នុងការបន្តការផ្តល់ជំនួយទាំងបច្ចេកទេស សម្ភារ និងថវិកាដល់កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជាតទៅទៀត រហូតសម្រេចបានជោគជ័យក្នុងការលុបបំបាត់ជំងឺអេដស៍ជាស្ថាពរ។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី!***

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជូនចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាជាភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានអញ្ជើញចូលរួមនៅក្នុងសម័យប្រជុំពេញអង្គដ៏មានសារៈសំខាន់នាពេលនេះ តាមរយៈការចូលរួមយ៉ាងសកម្មផ្តល់នូវគំនិតល្អៗ រួមជាមួយនឹងមតិដ៏ល្អ និងមានតម្លៃ សម្រាប់យកទៅប្រើប្រាស់ក្នុងការកែលម្អការអនុវត្តប្រយុទ្ធនឹងជំងឺអេដស៍ ឱ្យកាន់តែមានប្រសិទ្ធភាពថែមមួយកម្រិតទៀត។

ខ្ញុំសូមសម្តែងនូវការកោតសរសើរផងដែរ ជូនចំពោះអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺ អេដស៍ ដែលបានខិតខំរៀបចំសម័យប្រជុំពេញអង្គនេះឱ្យប្រព្រឹត្តទៅបានដោយរលូន និងសម្រេចបានជាផ្លែផ្កាគួរជាទីមោទនៈនាពេលនេះ។

ជាចុងក្រោយ ខ្ញុំសូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាជាភ្ញៀវជាតិ និងអន្តរជាតិទាំងអស់នូវពុទ្ធពរទាំងឡាយទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ និងធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

ខ្ញុំសូមប្រកាសបិទ "**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០១៩**" ជាផ្លូវការចាប់ពីពេលនេះតទៅ!

***សូមអរគុណ!***